# ភាសាខ្មែរ

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

This Khmer version of the draft law was made unofficially available in June 2014. It differs from the English draft posted on CCHR (http://sithi.org/admin/upload/law/Cybercrime%20Law.pdf) in April 2014 (which appears to be that commented on by the AIC in August 2013 (www.asiainternetcoalition.org/aic-comments-on-the-draft-cybercrime-law-for-cambodia/)), in that the prison terms and fines for many offenses are not specified and there are clarifying clauses added to several Articles. There are some minor changes to definitions of some offenses in Art. 28, and some changes to special penalties in Arts. 34 and 35, such as the elimination of a penalty that would allow the confiscation of a vehicle and the clarification that bans on professional activity may, depending on the circumstances of the offense, be for life. In substance, the two drafts show little difference, and the existence of each tends to corroborate the other.

**មាត្រា ១..** គោលបំណង

ច្បាប់នេះមានគោលបំណងកំណត់វិធានការអប់រំ បង្ការទប់ស្កាត់ និងបង្ក្រាបការប្រព្រឹត្តអំពើល្មើសនានា តាមប្រព័ន្ធបច្ចេក វិទ្យា។

**មាត្រា ២..** គោលដៅ

ច្បាប់នេះមានគោលដៅ៖
- ធានាការអនុវត្តច្បាប់ ប្រយុទ្ធប្រឆាំងនិងបង្ក្រាបរាល់បទល្មើសតាមប្រព័ន្ធ បច្ចេកវិទ្យា
- ធានាសុវត្ថិភាព និងការពារផលប្រយោជន៍ស្របច្បាប់ក្នុងការប្រើប្រាស់និងអភិវឌ្ឍន៍បច្ចេកវិទ្យា

**មាត្រា ៣..** វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តគ្រប់អំពើល្មើសទាំងអស់ដែលមានចែងនៅក្នុងច្បាប់នេះក្នុងករណី៖
- បទល្មើសដែលប្រព្រឹត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ
- បទល្មើសប្រព្រឹត្តនៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជា ហើយដែលប៉ះពាល់ដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ឬផល ប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ៤..** និយមន័យ

វាក្យស័ព្ទដែលប្រើប្រាស់ក្នុងក្របខណ្ឌនៃច្បាប់នេះ ត្រូវបានកំណត់ដូចតទៅ៖

១. ប្រព័ន្ធកុំព្យូទ័រ ឬកុំព្យូទ័រ សំដៅដល់ រាល់ឧបករណ៍ទាំងឡាយណា ទោះជាស្ថិតនៅដាច់ដោយឡែកតែឯង ឬជាបណ្តុំ នៃឧបករណ៍ដែលតភ្ជាប់គ្នាទៅវិញទៅមកឬឧបករណ៍ពាក់ព័ន្ធដែលក្នុងនោះមានឧបករណ៍ដំណើរការប្រព្រឹត្តិកម្មស្វ័យប្រវត្តិនៃទិន្នន័យ។

២. ប្រព្រឹត្តិកម្មស្វ័យប្រវត្តិនៃទិន្នន័យ សំដៅដល់ ដំណើរការនៃទិន្នន័យនៅក្នុងប្រព័ន្ធកុំព្យូទ័រដោយកម្មវិធីកុំព្យូទ័រ ។

៣. កម្មវិធីកុំព្យូទ័រ សំដៅដល់សំណុំបញ្ជាក្នុងទម្រង់ជាអក្សរ ឬលេខកូដ ឬគំនូសបំព្រួញ ឬតាមទម្រង់ណាមួយ នៅពេល ដែលបញ្ចូលទៅក្នុងកុំព្យូទ័រ អាចធ្វើឱ្យសម្រេចឬទទួលបានកិច្ចការ ឬលទ្ធផលជាក់លាក់ណាមួយតាមកុំព្យូទ័រ ឬតាម ប្រព័ន្ធអេឡិចត្រូនិចដែលអាចដំណើរការព័ត៌មាន។

៤. ទិន្នន័យកុំព្យូទ័រ សំដៅដល់អ្វីៗដែលតំណាងអោយហេតុការណ៍ ព័ត៌មាន ឬទស្សនាទានក្នុងទម្រង់ដែលអាចត្រូវបាន ដំណើរការនៅក្នុងប្រព័ន្ធកុំព្យូទ័រ ដោយរួមបញ្ចូលទាំងកម្មវិធីកុំព្យូទ័រ ដែលធ្វើអោយប្រព័ន្ធកុំព្យូទ័រដំណើរការនូវមុខងារ។

៥. ខ្លឹមសារ សំដៅដល់ខ្លឹមសារអេឡិចត្រូនិច ដោយរួមមានអត្ថបទ រូបភាព គំនូរជីវចល និមិត្តសញ្ញា សំលេង ឬវីដេអូ ។

៦. អ្នកផ្តល់សេវា សំដៅដល់៖

១. រាល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលផ្តល់សេវាដល់អ្នកប្រើប្រាស់ទាំងឡាយនូវលទ្ធភាពដើម្បីទំនាក់ទំនងតាមប្រព័ន្ធ កុំព្យូទ័រ

២. រាល់រូបវន្តបុគ្គល ឬនីតិបុគ្គលផ្សេងទៀត ដែលធ្វើប្រព្រឹត្តកម្ម ឬរក្សាទុកទិន្នន័យកុំព្យូទ័រ សម្រាប់បុគ្គលដែលចែងក្នុង កថាខ័ណ្ឌទី១ខាងលើ និងសម្រាប់អ្នកប្រើប្រាស់សេវាដទៃទៀត

**៧. ចរាចរណ៍ទិន្នន័យ** សំដៅដល់ រាល់ទិន្នន័យកុំព្យូទ័រទាំងឡាយណាដែលទាក់ទង ទៅនឹងទំនាក់ទំនងមួយតាមប្រព័ន្ធ កុំព្យូទ័រ និងត្រូវបានបង្កើតឡើងដោយមធ្យោបាយនេះ ដែលជាផ្នែកមួយនៃខ្សែសង្វាក់ទំនាក់ទំនងចង្អុលបង្ហាញប្រភព ដើមនៃទំនាក់ទំនង គោលដៅ ផ្លូវ ពេលវេលា កាលបរិច្ឆេទ ទំហំ មាឌ រយៈពេល ឬប្រភេទសេវាកម្មដែលបានប្រើសម្រាប់ ទំនាក់ទំនង។

**៨. វិធានការសន្តិសុខ** សំដៅដល់ ការប្រើប្រាស់នូវនីតិវិធី ឧបករណ៍ ឬកម្មវិធីកុំព្យូទ័រដាក់លាក់ ដើម្បីដាក់កំហិតឬហាម ឃាត់ក្រុមអ្នកប្រើប្រាស់ដែលមិនត្រូវបានអនុញ្ញាត ក្នុងការតភ្ជាប់ទៅកាន់ប្រព័ន្ធកុំព្យូទ័រ ***ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃ ក្នុងស្របតាមគោលការណ៍ណែនាំរបស់ គ.ប.ប ....។*** (ដដែកបន្ថែម)

**៩. អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធ បច្ចេកវិទ្យា ឬស្ថាប័នមានសមត្ថកិច្ចរបស់ប្រទេសដទៃទៀត

១០. គេហទំព័រ សំដៅដល់ទីកន្លែងនៅលើអ៊ិនធឺណិត ដែលអ្នកអាចស្វែងរកព័ត៌មានអំពីអ្វីមួយ

**១១. បុគ្គលដែលធ្វើសកម្មភាពដោយគ្មានសិទ្ធិ** សំដៅដល់បុគ្គលដែលធ្វើសកម្មភាពដូចខាងក្រោម៖
ក. មិនមានការអនុញ្ញាតដោយច្បាប់ឬកិច្ចសន្យា
ខ. លើសពីដែនកំណត់នៃការអនុញ្ញាត
គ. មិនមានការអនុញ្ញាតពីរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសិទ្ធិស្របច្បាប់ ដើម្បីប្រើប្រាស់ត្រួតពិនិត្យ ឬគ្រប់គ្រង ប្រព័ន្ធកុំព្យូទ័រ ឬដើម្បីធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រនៅក្នុងប្រព័ន្ធកុំព្យូទ័រ។

# ជំពូកទី២
# គណៈកម្មាធិការជាតិប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា

**មាត្រា ៥**..ការបង្កើតគណៈកម្មាធិការជាតិប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាត្រូវបានបង្កើតគណៈកម្មាធិការ ជាតិប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា សរសេរកាត់ថា គ.ប.ប. ។

**មាត្រា ៦**..សមាសភាពរបស់ គ.ប.ប.
សមាសភាពរបស់គណៈកម្មាធិការជាតិប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធបច្ចេក វិទ្យាមានដូចតទៅ៖

- នាយករដ្ឋមន្ត្រី ប្រធាន
- ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
- រដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក
- រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក
- រដ្ឋលេខាធិការក្រសួងការបរទេស សមាជិក
- អគ្គស្នងការនគរបាលជាតិ សមាជិក
- តំណាងគណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម សមាជិក
- អគ្គលេខាធិការ NiDA សមាជិក
- តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សមាជិក
- តំណាងសភាពាណិជ្ជកម្មកម្ពុជា សមាជិក
- អគ្គលេខាធិការនៃគ.ប.ប. សមាជិកអចិន្ត្រៃយ៍

ការតែងតាំងសមភាពនៃគណៈកម្មាធិការជាតិប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក។

**មាត្រា ៧**..ភារកិច្ចរបស់ គ.ប.ប
គណៈកម្មាធិការជាតិប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាមានភារកិច្ចដូចតទៅ៖

- លើកសំណើរជូនរាជរដ្ឋាភិបាលនូវយុទ្ធសាស្ត្រ ផែនការសកម្មភាព ព្រមទាំងកម្មវិធីពាក់ព័ន្ធនឹងការងារសន្តិសុខ ព័ត៌មាន
- ពិគ្រោះយោបល់និងផ្តល់អនុសាសន៍ដល់អគ្គលេខាធិការដ្ឋាន គ.ប.ប.
- ត្រួតពិនិត្យដំណើរការការងារនៃអគ្គលេខាធិការដ្ឋាន គ.ប.ប.
- ចេញសេចក្តីសម្រេច និងសេចក្តីណែនាំចាំបាច់នានាដល់ បណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដើម្បីធានាបាន ប្រសិទ្ធិភាពសន្តិសុខព័ត៌មាន

- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលប្រចាំឆមាស និងប្រចាំឆ្នាំ
- ទទួលភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល

**មាត្រា ៨**..អគ្គលេខាធិការដ្ឋាននៃ គ.ប.ប.

គ.ប.ប.មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការដែលជាអង្គភាពប្រតិបត្តិ។

អគ្គលេខាធិការដ្ឋាននៃ គ.ប.ប. ដឹកនាំដោយអគ្គលេខាធិការមួយរូបអមអោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។

អគ្គលេខាធិការ និងអគ្គលេខាធិការរងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ គ.ប.ប. ត្រូវកំណត់អនុក្រឹត្យ។

**មាត្រា ៩**..ភារកិច្ចអគ្គលេខាធិការដ្ឋាននៃ គ.ប.ប.

អគ្គលេខាធិការដ្ឋាន នៃ គ.ប.ប. មានភារកិច្ចដូចខាងក្រោម៖

- អនុវត្តច្បាប់ បទបញ្ជា និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងបទល្មើសបច្ចេកវិទ្យាជាធរមាន
- តាមដានស៊ើបអង្កេត ត្រួតពិនិត្យ និងធ្វើការសិក្សាស្រាវជ្រាវ ព្រមទាំងលើកផែនការនានាពាក់ព័ន្ធនឹងបទល្មើស បច្ចេកវិទ្យា
- ដឹកនាំ គ្រប់គ្រង ទប់ស្កាត់ បង្ក្រាប ប្រយុទ្ធប្រឆាំងបទល្មើស បច្ចេកវិទ្យានៅក្នុងព្រះរាជាណាចក្រកម្ពុជា
- កំណត់និយាម បទដ្ឋានគតិយុត្តិ ផែនការយុទ្ធសាស្ត្រនានាទាក់ទងនឹងបច្ចេកវិទ្យា
- ត្រួតពិនិត្យ វាយតម្លៃ និងចេញវិញ្ញាបនប័ត្រទទួលស្គាល់គុណភាព សុវត្ថិភាព សន្តិសុខនៃកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ កម្មវិធីកុំព្យូទ័រ និងការផ្តល់សេវាបច្ចេកវិទ្យាដទៃទៀត
- ជំរុញ ផ្សព្វផ្សាយ បណ្តុះបណ្តាល លើកកំពស់ការយល់ដឹងអំពីបច្ចេកវិទ្យា
- សហការជាមួយបណ្តាក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល អង្គការជាតិ អង្គការក្នុងតំបន់ និងអន្តរជាតិនានា ដើម្បីតាមដានស៊ើបអង្កេត ត្រួតពិនិត្យ ធ្វើការសិក្សាស្រាវជ្រាវ គ្រប់គ្រង ទប់ស្កាត់ បង្ក្រាប ប្រយុទ្ធប្រឆាំងបទល្មើស
- តែងតាំង ផ្លាស់ប្តូរ និងគ្រប់គ្រង ឬលើកសំណើរតែងតាំង ផ្លាស់ប្តូរ មន្ត្រីរាជការក្រោមឱវាទក្នុងអគ្គលេខាធិការដ្ឋាន គ.ប.ប.
- ពិនិត្យនិងលើកគម្រោងថវិការប្រចាំឆ្នាំរបស់ គ.ប.ប.
- ធ្វើរបាយការណ៍អំពីសកម្មភាពទាំងឡាយរបស់ខ្លួនជូន គ.ប.ប.និងរាជរដ្ឋាភិបាល
- ទទួលភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពី គ.ប.ប. និងរាជរដ្ឋាភិបាល

**មាត្រា ១០**..មន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃ គ.ប.ប.

មន្ត្រីបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋានរួមមានមន្ត្រីរាជការដែល ត្រូវបានតែងតាំង ឬផ្ទេរមកបម្រើការងារក្នុងអគ្គលេខា ធិការដ្ឋាន និងមន្ត្រីដែលត្រូវបានជ្រើសរើសអោយមកបម្រើការងារតាមកិច្ចសន្យា។

មន្ត្រីទាំងអស់ខាងលើនេះត្រូវគោរពតាមបទប្បបញ្ញាត្តិទាំងឡាយនច្បាប់និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធដទៃជាធរមាន។

អគ្គលេខាធិការ គ.ប.ប. អាចជ្រើសរើសអ្នកជំនាញការ អ្នកឯកទេស និងអ្នកស្រាវជ្រាវជាតិ អន្តរជាតិ ជាប់កិច្ចសន្យា ឬដោយស្មគ្រ័ចិត្តអោយជួយផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធប្រឆាំងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា។

**មាត្រា ១១**..បណ្តាញនៃអគ្គលេខាធិការដ្ឋាន គ.ប.ប.

អគ្គលេខាធិការដ្ឋាន គ.ប.ប. អាចមានការិយាល័យរបស់ខ្លួននៅគ្រប់ រាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជាដើម្បីធ្វើការ បណ្តាញការងារ របស់ខ្លួន។ ការិយាល័យនេះអនុវត្តការងាររបស់ខ្លួនក្រោមការដឹកនាំ របស់អគ្គលេខាធិការ នៃអគ្គលេខា ធិការដ្ឋាន គ.ប.ប.។ ការិយាល័យ នេះដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១២**..ថវិការនិងធនធានរបស់ គ.ប.ប.

គ.ប.ប. មានកញ្ចប់ថវិការដោយឡែកសម្រាប់ដំណើរការដែលស្ថិតនៅក្នុងកញ្ចប់ថវិការ របស់ទីស្តីការគណៈរដ្ឋ មន្ត្រី។

គ.ប.ប. ទទួលធនធានចាំបាច់នានាពី រាជរដ្ឋាភិបាលនិងមានសិទ្ធិទទួលនូវអំណោយឬជំនួយពីអង្គការជាតិ អន្តរជាតិនានា។

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ប.ប. ជាអាណាប័កទទួលសិទ្ធិ។

## ជំពូកទី៣
## នីតិវិធី

**មាត្រា ១៣**..នីតិវិធីសម្រាប់អនុវត្តចំពោះបទល្មើសបច្ចេកវិទ្យា

នីតិវិធីសម្រាប់អនុវត្តចំពោះបទល្មើសបច្ចេកវិទ្យាដែលមានចែងក្នុងច្បាប់នេះត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ កាលណាពុំមានចែងដោយឡែកនៅក្នុងច្បាប់នេះ។

**មាត្រា ១៤**.. មន្ត្រីមានសមត្ថកិច្ចនៅក្នុងការស៊ើបអង្កេតបទល្មើសបច្ចេកវិទ្យា

អគ្គលេខាធិការ អគ្គលេខាធិការរង និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ប.ប.ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាល យុត្តិធម៌មានសមត្ថកិច្ចស៊ើបអង្កេតលើបទល្មើសបច្ចេកវិទ្យាដែលមានចែងក្នុងច្បាប់នេះ និងបទល្មើសបច្ចេកវិទ្យាដែល មានចែងនៅក្នុងក្រមព្រហ្មទណ្ឌ។

បុគ្គលឬអង្គភាពដែលបានដឹងអំពីបទល្មើសបច្ចេកវិទ្យាទាំងឡាយដែលមានចែងក្នុងច្បាប់នេះ និងបទល្មើសបច្ចេកវិទ្យាដែល មានចែងក្នុងក្រមព្រហ្មទណ្ឌ ត្រូវប្ដឹងទៅអគ្គលេខាធិការដ្ឋាន គ.ប.ប. អំពីរឿងហេតុនៃបទល្មើសទាំងនេះ។

**មាត្រា ១៥**.. ការផ្ដល់នីតិសម្បទាចំពោះមន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ប.ប.

អគ្គលេខាធិការនិងអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគ.ប.ប.មានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដោយពេញច្បាប់ ដើម្បីបំពេញមុខងាររបស់ខ្លួន។

មន្ត្រីនៃនៃអគ្គលេខាធិការដ្ឋានគ.ប.ប.អាចទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធី ព្រហ្មទណ្ឌ។

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ប.ប. មានភារកិច្ចរៀបចំបញ្ជីឈ្មោះមន្ត្រីនៃអគ្គលេខាធិការដ្ឋានគ.ប.ប. ដែលត្រូវ ទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា ១៦**.. អំណាចស៊ើបអង្កេតរបស់អគ្គលេខាធិការដ្ឋាន គ.ប.ប.

មន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ប.ប. ដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចស៊ើបអង្កេតបទល្មើស បច្ចេកវិទ្យា។ បើសិនជាក្នុងករណីស៊ើបអង្កេតបទល្មើសបច្ចេកវិទ្យាហើយរកឃើញបទល្មើសផ្សេងទៀតដែលមានអង្គហេតុទាក់ទិននឹងបទល្មើសដែលកំពុងស៊ើបអង្កេត មន្ត្រីនៃអគ្គលេខាធិការដ្ឋានគ.ប.ប. ត្រូវប្ដឹង ទៅអាជ្ញាធរមានសមត្ថកិច្ច។

អគ្គលេខាធិការដ្ឋាន គ.ប.ប. មិនអាចចាប់ផ្ដើមស៊ើបអង្កេតបទល្មើសអ្វីក្រៅពីបទល្មើសបច្ចេកវិទ្យាបានទេ លើកលែងតែមាន បញ្ជាពីអាជ្ញាធរតុលាការអោយអគ្គលេខាធិការដ្ឋាន គ.ប.ប. ស៊ើបអង្កេតបទល្មើសអ្វីក្រៅពីបទល្មើសបច្ចេកវិទ្យា។

តុលាការអាចបញ្ជាអោយអគ្គលេខាធិការដ្ឋាន គ.ប.ប. ធ្វើកោសល្យវិច័យនានាដើម្បីជួយដល់ការវិនិច្ឆ័យរបស់តុលាការ។

នៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតទាំងនេះនិងដោយបដិប្បញ្ញត្តិទៅនឹងមាត្រា៨៥ (អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្ដែង) មាត្រា៩១ (ការឆែកឆេរ) មាត្រា៩៤ (បទបញ្ជាអោយចូលខ្លួនក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្ដែង) និងមាត្រា១១៤ (ការបញ្ជាអោយចូលខ្លួនការស៊ើបអង្កេតបឋម) នៃក្រមនីតិវិធីព្រហ្មទណ្ឌ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ប.ប. ឬតំណាងដែលខ្លួនបានចាត់តាំងត្រឹមត្រូវមានតួនាទីដឹកនាំ សម្របសម្រួលនិងត្រួតពិនិត្យបេសកម្មរបស់មន្ត្រីទាំងនេះជំនួស
តួនាទីរបស់ព្រះរាជអាជ្ញារហូតដល់មានការឃាត់ខ្លួនជនសង្ស័យ។

បន្ទាប់ពីមានការឃាត់ខ្លួន ព្រះរាជអាជ្ញាអនុវត្តអំណាចរបស់ខ្លួនដូចបានកំណត់នៅ ក្នុងបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

នៅចុងបញ្ចប់នៃការស៊ើបអង្កេតនីមួយៗ អគ្គលេខាធិការដ្ឋាន គ.ប.ប. ត្រូវបញ្ជូនរាល់នីតិវិធីទាំងអស់ទៅព្រះរាជអាជ្ញា ដើម្បីចាត់ការបន្ត ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា ១៧**.. ការរក្សាទុកទិន្នន័យកុំព្យូទ័រ និងចរាចរណ៍ទិន្នន័យ

១. នៅក្នុងករណីបន្ទាន់ ឬមានតម្រូវការចាំបាច់ បើសិនជាទិន្នន័យឬក៏ការបង្ហាញភស្តុតាងចង្អុលអោយឃើញនូវការ ត្រៀមរៀបចំឬក៏ដំណើរការនៃបទឧក្រិដ្ឋដោយមធ្យោបាយប្រព័ន្ធកុំព្យូទ័រ ការបញ្ជាត្រូវបានធ្វើឡើងដោយអគ្គលេខាធិការដ្ឋាន គ.ប.ប. ដើម្បីរក្សាទុកទិន្នន័យកុំព្យូទ័រឬទិន្នន័យដែលទាក់ទងទៅនឹងចរាចរណ៍ទិន្នន័យអោយបានឆាប់រហ័ស សម្រាប់គោល បំណងក្នុងការប្រមូលយកនូវភស្តុតាង ឬកំណត់អត្តសញ្ញាណអ្នកប្រព្រឹត្ត។

២. តាមការស្នើសុំរបស់អគ្គលេខាធិការដ្ឋាន គ.ប.ប. ព្រះរាជអាជ្ញាចេញដីកាបញ្ជារក្សាទុកទិន្នន័យកុំព្យូទ័រ និង ចរាចរណ៍ទិន្នន័យក្នុងកំឡុងពេលស៊ើបអង្កេតបទឧក្រិដ្ឋ ហើយក្នុងកំឡុងពេលជំនុំជំរះក្ដីដោយដីកាតុលាការ។

៣. វិធានដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេល ៩០ថ្ងៃ ហើយអាចពន្យាបានតែម្ដងគត់ ដោយមិនត្រូវលើសពីរយៈពេល ៣០ថ្ងៃឡើយ។

៤. ដីការបស់ព្រះរាជអាជ្ញា ឬដីកាតុលាការត្រូវបានបញ្ជូនភ្លាម ទៅកាន់រាល់អ្នកផ្ដល់សេវាណា ឬរាល់បុគ្គលណាដែល ជាកម្មសិទ្ធរបស់ទិន្នន័យដែលមានចែងក្នុងកថាខណ្ឌទី១។ អ្នកផ្ដល់សេវាកម្ម ឬក៏បុគ្គលនោះ មានកាតព្វកិច្ចធ្វើការរក្សា ទុកព័ត៌មានទាំងនោះប្រកបដោយប្រសិទ្ធិភាព ស្ថិតក្នុងលក្ខខណ្ឌសម្ងាត់។

៥. ក្នុងករណីដែលទិន្នន័យសំដៅទៅលើចរាចរណ៍ទិន្នន័យស្ថិតក្រោមកម្មសិទ្ធរបស់អ្នកផ្តល់សេវាច្រើន អ្នកផ្តល់សេវាដែល ចែងក្នុងកថាខណ្ឌទី៤ខាងលើ ត្រូវមានកាតព្វកិច្ចផ្តល់ភ្លាមនូវព័ត៌មានចាំបាច់ទាំងឡាយទៅអោយអគ្គលេខាធិការដ្ឋាន គ.ប.ប. ដើម្បីធ្វើការកំណត់អត្តសញ្ញាណរបស់អ្នកផ្តល់សេវាដទៃទៀត ក្នុងគោលបំណងដើម្បីដឹងនូវរាល់ជាតុទាំងអស់ ដែលបានប្រើប្រាស់ក្នុងសង្វាក់ទំនាក់ទំនង។ ចំពោះបុគ្គលដែលមានចែងក្នុង កថាខណ្ឌទី៤ខាងលើ ក៏ត្រូវអនុវត្តដូច ក្នុងកថាខណ្ឌទី៥នេះផងដែរ។

៦. រហូតទាល់តែដល់ទីបញ្ចប់នៃការស៊ើបអង្កេតបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវមានកាតព្វកិច្ចផ្តល់យោបល់ជាលាយ លក្ខណ៍អក្សរនូវបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេតបទឧក្រិដ្ឋ និងទិន្នន័យរបស់បុគ្គលដែលត្រូវបានរក្សាទុក។

**មាត្រា ១៨**.. ការថតចម្លងទិន្នន័យ

១. ស្ថិតក្នុងរង្វង់នៃពេលវេលាដូចបានកំណត់ក្នុងមាត្រា២០ កថាខណ្ឌទី៣ខាងលើ ព្រះរាជអាជ្ញាស្ថិតក្នុងមូលដ្ឋាននៃ សិទ្ធិអំណាចរបស់ខ្លួនដែលត្រូវបានផ្តល់អោយជាពិសេសដោយអគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍ ឬតាមតម្រូវការសមស្រប ដោយអគ្គព្រះរាជអាជ្ញានៃតុលាការកំពូល ឬក៏ដីការតុលាការ ក្នុងការរឹបអូសឧបករណ៍ដែលផ្ទុកទិន្នន័យកុំព្យូទ័រ ចរាចរណ៍ ទិន្នន័យ ឬទិន្នន័យដែលទាក់ទងទៅនឹង អ្នកប្រើប្រាស់ទទួលបានពីបុគ្គលឬអ្នកផ្តល់សេវា ដើម្បីធ្វើការថតចំលង ប្រើប្រាស់ ធ្វើជាភស្តុតាង។

២. បើសិនជាឧបករណ៍នោះផ្ទុកទិន្នន័យកុំព្យូទ័រសំដៅទៅលើទិន្នន័យដែលចាំបាច់សម្រាប់អគ្គលេខាធិការដ្ឋាន គ.ប.ប. ដើម្បីថតចំលង ព្រះរាជអាជ្ញាដូចបានរៀបរាប់ក្នុងកថាខណ្ឌទី១ខាងលើឬតុលាការ ត្រូវចេញដីការឹបអូសដោយបង្ខំ។ ក្នុង កំឡុងពេលជំនុំជំរះក្តី ដីការឹបអូស ដោយបង្ខំត្រូវបញ្ជូនទៅកាន់ព្រះរាជអាជ្ញាដែលត្រូវចាត់វិធានការណ៍អនុវត្ត តាមរយៈអគ្គ លេខាធិការដ្ឋាន គ.ប.ប. ។

៣. ការថតចំលងដែលមានចែងក្នុងកថាខណ្ឌទី១ ត្រូវធ្វើអោយ សម្រេចបានដោយមធ្យោបាយបច្ចេកទេស និងមាននីតិវិធី ច្បាស់លាស់ក្នុងការផ្តល់នូវសុច្ចរិតភាពនៃព័ត៌មានដែលបានផ្ទុក។ មធ្យោបាយបច្ចេកទេស និងនីតិវិធីដែលចែងនៅទីនេះ ត្រូវ កំណត់ដោយ បទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាន គ.ប.ប. ។ (បន្ថែម)

**មាត្រា ១៩**.. ការស្វែងរក ការរឹបអូសទិន្នន័យកុំព្យូទ័រ

១. ក្នុងគោលបំណងសម្រាប់ការស្វែងរក ឬប្រមូលភស្តុតាងដែលចាំបាច់ក្នុងការ ស៊ើបអង្កេតទៅលើប្រព័ន្ធកុំព្យូទ័រ ឬមធ្យោបាយរក្សាទុកទិន្នន័យកុំព្យូទ័រ ព្រះរាជអាជ្ញាឬតុលាការអាចចេញដីកាក្នុងការស្វែងរក ។

២. បើសិនជាអគ្គលេខាធិការដ្ឋាន គ.ប.ប. ឬតុលាការពិចារណាឃើញថា ឧបករណ៍ដែលបានរឹបអូសទាំងនោះមាននូវទិន្នន័យដូចមានចែងក្នុងកថាខណ្ឌទី១ អាចផ្តល់ផលប៉ះពាល់យ៉ាងខ្លាំង ទៅដល់សកម្មភាពដែលប្រព្រឹត្តដោយបុគ្គលដែលជាម្ចាស់កម្មសិទ្ធិ អគ្គលេខាធិការដ្ឋាន គ.ប.ប. ឬតុលាការអាច ចេញបញ្ជាអោយថតចំលងធ្វើជាភស្តុតាង និងអាចសម្រេចបានដោយយោងទៅតាមមាត្រា២១ កថាខណ្ឌទី៣។

៣. នៅក្នុងពេលស៊ើបអង្កេតប្រព័ន្ធកុំព្យូទ័រ ឬក៏មធ្យោបាយរក្សាទុកទិន្នន័យកុំព្យូទ័រ មានការរកឃើញថាទិន្ន័យកុំព្យូទ័រ ដែលកំពុងស្រាវជ្រាវនោះគឺមាននៅក្នុងប្រព័ន្ធកុំព្យូទ័រដទៃទៀត ឬមធ្យោបាយរក្សាទុកទិន្នន័យកុំព្យូទ័រដទៃទៀត នឹងដែល អាចភ្ជាប់ទៅតាមតាមរយៈប្រព័ន្ធ កុំព្យូទ័រដំបូង ឬមធ្យោបាយរក្សាទុកទិន្នន័យកុំព្យូទ័រដំបូង អគ្គលេខាធិការដ្ឋាន គ.ប.ប. ឬតុលាការចេញបញ្ជាភ្លាមក្នុងការផ្តល់អំណាចអោយមានការស្រាវជ្រាវរុករក ក្នុងគោលបំណងបើកការស៊ើបអង្កេតរាល់ ប្រព័ន្ធកុំព្យូទ័រ ឬមធ្យោបាយរក្សាទុកទិន្នន័យកុំព្យូទ័រទាំងអស់នោះ។

**មាត្រា ២០**.. លក្ខខណ្ឌនិងការការពារ

១. ការភ្ជាប់ទៅកាន់ប្រព័ន្ធកុំព្យូទ័រ ក៏ដូចជាការស្ទាក់ចាប់ ឬក៏ថតទុកនៃទំនាក់ទំនង ដែលបានធ្វើឡើងដោយមធ្យោបាយប្រព័ន្ធកុំព្យូទ័រ ត្រូវបានធ្វើឡើងនៅពេលដែលមានប្រយោជន៍ក្នុងការស្វែងរកសច្ចៈភាព និងការពិត ឬកំណត់អត្តសញ្ញាណរបស់អ្នកប្រព្រឹត្ត មិនអាចយកមកធ្វើជាមូលដ្ឋាននៃភស្តុតាងដទៃទៀតឡើយ។

២. វិធានការណ៍សំដៅទៅលើកថាខណ្ឌទី១អាចធ្វើឡើងដោយសារសិទ្ធអំណាចរបស់ព្រះរាជអាជ្ញាដែលត្រូវបានផ្តល់អោយ ជាពិសេសដោយអគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍ ឬការតម្រូវសមស្របដោយអគ្គព្រះរាជអាជ្ញានៃតុលាការកំពូល **និងសម្រាប់បទល្មើសពុករលួយ ធ្វើឡើងដោយអគ្គព្រះរាជអាជ្ញានៃការិយាល័យប្រឆាំងអំពើពុករលួយជាតិ** ដោយអង្គភាពស៊ើបអង្កេតបទឧក្រិដ្ឋជាមួយនឹងការជួយពីបុគ្គលជំនាញ ដែល មានកាតព្វកិច្ចក្នុងការរក្សាទុកនូវភាព សម្ងាត់នៃសកម្មភាពដំណើរការផងដែរ។

៣. សិទ្ធិអំណាចដែលមានចែងក្នុងកថាខណ្ឌទី២ខាងលើ ត្រូវធ្វើឡើងក្នុងរយៈពេល ៣០ថ្ងៃ ហើយអាចពន្យាបានម្តងគត់ ស្ថិតក្រោមលក្ខខណ្ឌដូចគ្នាដោយមិនអោយលើសពីរយៈពេល ៣០ថ្ងៃឡើយ។ វិធានការណ៍ទាំងនេះគឺមានរយៈពេល អតិបរមាចំនួន០៤ខែ។

៤. រហូតដល់ទីបញ្ចប់នៃការស៊ើបអង្កេតបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវមានកាតព្វកិច្ចក្នុងការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់បុគ្គលទាំងឡាយដែលវិធានការណ៍ទាំងឡាយត្រូវបានអនុវត្តន៍ដូចដែលបានចែងក្នុងកថាខណ្ឌទី១។( តើព្រះរាជអាជ្ញាអាចធ្វើបានទេ ? )

៥. នីតិវិធីក្រមព្រហ្មទណ្ឌដែលទាក់ទងទៅនឹងការថតសំលេង និងវីដេអូត្រូវ បានអនុវត្តន៍ផងដែរ។

## ជំពូកទី៤
## បទល្មើស

**មាត្រា ២១**.. ការភ្ជាប់ដោយខុសច្បាប់

១. ជនណាដែលធ្វើការភ្ជាប់ដោយគ្មានសិទ្ធិទៅកាន់ប្រព័ន្ធកុំព្យូទ័រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦ (ប្រាំមួយ) ខែទៅ ៣ (បី) ឆ្នាំ និងពិន័យប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀលទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល។

២. សកម្មភាពដែលមានចែងក្នុងកថាខ័ណ្ឌទី១ ដោយធ្វើឡើងក្នុងគោលបំណងទាញយកនូវទិន្នន័យ កុំព្យូទ័រ ត្រូវផ្តន្ទា ទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀលទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។

៣. សកម្មភាពដែលមានចែងក្នុងកថាខ័ណ្ឌទី១ និង/ឬ ទី២ ដែលត្រូវបានធ្វើឡើងដោយរំលោភ បំពានលើវិស័យការសន្តិសុខ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ១២ (ដប់ពីរ) ឆ្នាំ និងពិន័យប្រាក់ពី ៦ ០០០ ០០០ (ប្រាំមួយលាន) រៀលដល់ ២៤ ០០០ ០០០ (ម្ភៃបួនលាន) រៀល។

**មាត្រា ២២**.. ចារកម្មទិន្នន័យ

១. ជនណាដែលទាញយកទិន្នន័យសំរាប់ផ្ទាល់ខ្លួន ឬសម្រាប់អ្នកដទៃ ដោយគ្មានការអនុញ្ញាត ហើយទិន្ន័យនោះ មិនមែនជារបស់ខ្លួននិងត្រូវបានការពារយ៉ាងពិសេសទៅនឹងការភ្ជាប់ដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី) ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀលទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

២. ទិន្ន័យដែលមានចែងក្នុងកថាខ័ណ្ឌទី១ខាងលើសំដៅដល់ទិន្ន័យដែលត្រូវបានរក្សាទុកបញ្ជូនតាមបែប អេឡិកត្រូនិក ម៉ាញេទិករឺទំរង់ទាំងឡាយណាដែលមិនអាចមើលឃើញដោយផ្ទាល់។

**មាត្រា ២៣**.. ការស្ទាក់ចាប់ដោយខុសច្បាប់

ជនណាដែលធ្វើការស្ទាក់ចាប់ដោយគ្មានសិទ្ធិតាមមធ្យោបាយបច្ចេកទេសនៃការបញ្ជូនទិន្នន័យកុំព្យូទ័រមិនមែនជាសាធារណៈ ទៅកាន់ មកពី ឬក៏នៅក្នុងប្រព័ន្ធកុំព្យូទ័រ ដោយរួមមាននូវការបញ្ជូនទិន្នន័យបែប អេឡិចត្រូម៉ាញ៉េទិចចេញពីប្រព័ន្ធកុំព្យូទ័រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ ៧ (ប្រាំពីរ) ឆ្នាំ និងពិន័យប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀលទៅ ១៤ ០០០ ០០០ (ដប់បួនលាន) រៀល។

**មាត្រា ២៤**.. ការជ្រៀតជ្រែកទិន្នន័យ

ជនណាដែលធ្វើការកែប្រែ ការលុប ការធ្វើអោយខូច ឬក៏ការដាក់កំហិតនូវទិន្នន័យកុំព្យូទ័រដោយគ្មានសិទ្ធិ ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំទៅ ៧ (ប្រាំពីរ) ឆ្នាំ និងពិន័យប្រាក់ពី ៤ ០០០ ០០០ (បួនលាន)រៀលដល់ ១៤ ០០០ ០០០ (ដប់បួនលាន) រៀល។

**មាត្រា ២៥**.. ការផ្ទេរទិន្នន័យដោយគ្មានការអនុញ្ញាត

ជនណាដែលផ្ទេរទិន្នន័យដោយគ្មានការអនុញ្ញាតចេញពីប្រព័ន្ធកុំព្យូទ័រ ឬដោយប្រើប្រាស់មធ្យោបាយផ្ទុកទិន្នន័យកុំព្យូទ័រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី)ឆ្នាំទៅ១២ (ដប់ពីរ) ឆ្នាំនិងពិន័យប្រាក់ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀលទៅ ២៤ ០០០ ០០០ (ម្ភៃបួនលាន) រៀល។

**មាត្រា ២៦**.. ការជ្រៀតជ្រែកប្រព័ន្ធ

ជនណាដែលធ្វើសកម្មភាពដោយគ្មានសិទ្ធិ ដែលបណ្តាលអោយមានការរំខានយ៉ាងធ្ងន់ធ្ងរទៅលើមុខងាររបស់ប្រព័ន្ធកុំព្យូទ័រ ដោយការបញ្ចូល ការ បញ្ជូន ការកែប្រែ ឬការធ្វើអោយខូចដល់ទិន្នន័យកុំព្យូទ័រ ឬដោយការកំហិតការភ្ជាប់ទៅកាន់ទិន្នន័យ ទាំងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំទៅ ១៥ (ដប់ប្រាំ) ឆ្នាំ និងពិន័យប្រាក់ពី ៦ ០០០ ០០០ (ប្រាំមួយលាន) រៀលទៅ ៣០ ០០០ ០០០ (សាមសិបលាន) រៀល។

**មាត្រា ២៧**.. រូបអាសអាភាសកុមារ

១. ជនណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

ក. ផលិតរូបអាសអាភាសកុមារសំរាប់យកទៅចែកចាយតាមរយៈប្រពន្ធ័កុំព្យូទ័រ

ខ. ផ្តល់ឬដាក់អោយមានរូបអាសអាភាសកុមារតាមរយៈប្រពន្ធ័កុំព្យូទ័រ

គ. ចែកចាយឬបញ្ជូនរូបអាសអាភាសកុមារតាមរយៈប្រពន្ធ័កុំព្យូទ័រ

ឃ. ទាញយកឬផ្តល់អោយអ្នកដទៃនូវរូបអាសអាភាសកុមារតាមរយៈប្រពន្ធ័កុំព្យូទ័រ

ង. ធ្វើជាម្ចាស់រូបអាសអាភាសកុមារនៅក្នុងប្រពន្ធ័កុំព្យូទ័រឬឧបករណ៍ស្តុកទិន្នន័យ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៥ (ប្រាំ)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀលទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។

២. រូបអាសអាភាសកុមារដែលមានចែងក្នុងកថាខណ្ឌទី១ខាងលើ រួមមានរូបអាសគ្រាមដែលអាចមើល ឃើញនឹងភ្នែកបាន៖

ក. អនីតិជនដែលសំដែងចេញនូវការប្រព្រឹត្តិអារម្មណ៍ផ្លូវភេទ

ខ. បុគ្គលម្នាក់ដែលបញ្ចេញកាយវិការដូចនិងអនីតិជនដែលសំដែងចេញនូវការប្រព្រឹត្តិ អារម្មណ៍ផ្លូវភេទ

គ. រូបភាពជាក់ស្តែងដែលតំណាងអោយអនីតិជនដែលសំដែងចេញនូវការប្រព្រឹត្តិអារម្មណ៍ ផ្លូវភេទ

**មាត្រា ២៨**.. ខ្លឹមសារនិងគេហទំព័រ

ជនណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

១. តាក់តែងមាតិកាព័ត៌មានដែលធ្វើអោយអន្តរាយដល់ឯករាជ្យភាព អធិបតេយ្យភាព បូណ៌ភាពទឹកដីរបស់ ព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលដល់ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។

២. ធ្វើការផ្សព្វផ្សាយខ្លឹមសារអ្វីដែលនាំអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដោយ ញុះញង់ដោយផ្ទាល់ អោយមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើហឹង្សា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលដល់ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។

៣. ផ្សព្វផ្សាយខ្លឹមសារឬផ្សាយបន្តនូវព័ត៌មានដែលបណ្តាលអោយប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថេរភាព នយោបាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលដល់ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។

៤. ផ្សព្វផ្សាយខ្លឹមសារឬផ្សាយបន្តព័ត៌មានមិនពិតដែលជាការជេរប្រមាថការមើលងាយដល់ ស្ថាប័នជាតិ ត្រូវផ្តន្ទា ទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលដល់ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។

៥. ផ្សព្វផ្សាយខ្លឹមសារអ្វីដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិជាអាទិ៍៖

ក. ព័ត៌មានដែលញុះញង់អោយមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា មតិឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន និងស្ថានភាពដទៃទៀត

ខ. អត្ថបទឬរូបអាសអាភាស និងរូបភាពនៃអំពើហឹង្សា

គ. ការមួលបង្កាច់ បរិហារកេរ្តិ៍ និងការជេរប្រមាថ

ឃ. រូបភាពដែលប្រមាថមើលងាយប្រៀបធៀបមនុស្សទៅនឹងសត្វតិរច្ឆាន

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលដល់ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។

៦. តាក់តែងខ្លឹមសារគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមប្រឆាំងនឹងបុគ្គល ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលដល់ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។ ចំពោះប្រភេទនៃការគំរាមកំហែងត្រូវអនុវត្ត តាមច្បាប់និងបទប្បញ្ញត្តជាធរមាន។

**មាត្រា ២៩**.. កម្មសិទ្ធិបញ្ញា

សម្រាប់បទល្មើសដែលទាក់ទងទៅនឹងកម្មសិទ្ធិបញ្ញាគឺត្រូវបានអនុវត្តទៅតាមច្បាប់សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលនៃព្រះរាជាណាចក្រកម្ពុជាដែលចូលជាធរមាន។

**មាត្រា ៣០**.. ការឆបោកតាមរយៈកុំព្យូទ័រ

ជនណាដែលមានចេតនាក្នុងការធ្វើអោយបាត់បង់កម្មសិទ្ធិ (property) របស់អ្នកដទៃតាមរយៈការ បញ្ចូល ការកែប្រែ ឬលុបទិន្នន័យកុំព្យូទ័រ ការរាំងនូវការភ្ជាប់ទៅកាន់ទិន្នន័យ ការជ្រៀតជ្រែកទៅលើ មុខងាររបស់ប្រព័ន្ធកុំព្យូទ័រក្នុងគោល បំណងទទួលបានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សម្រាប់ខ្លួនឯង ឬក៏អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំទៅ ១២ (ដប់ពីរ)ឆ្នាំ និងពិន័យប្រាក់ពី ៦ ០០០ ០០០ (ប្រាំមួយលាន) រៀលទៅ ២៤ ០០០ ០០០ (ម្ភៃបួនលាន) រៀល។

**មាត្រា ៣១**.. ការក្លែងបន្លំតាមរយៈកុំព្យូទ័រ

ជនណាដែលមានចេតនាក្នុងការបញ្ចូល ការកែប្រែឬលុបទិន្នន័យកុំព្យូទ័រ ការរាំងទៅលើការភ្ជាប់ ទៅកាន់ទិន្នន័យទាំងនោះ ដោយគ្មានសិទ្ធិ ក្នុងគោលបំណងប្រើប្រាស់សម្រាប់ផ្លូវច្បាប់ ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ ៧ (ប្រាំពីរ) ឆ្នាំនិងពិន័យប្រាក់ពី ៤ ០០០ ០០០ (មួយលាន) រៀលទៅ ១៤ ០០០ ០០០ (ដប់បួនលាន)រៀល។

**មាត្រា ៣២**.. ការប្រើឧបករណ៍ក្នុងផ្លូវខុស

១. ជនណាដែលធ្វើសកម្មភាពណាមួយខាងក្រោម ដោយគ្មានសិទ្ធិ៖

ក. ការផលិត ការលក់ ការធ្វើលទ្ធកម្មប្រើប្រាស់ ការនាំចូល ការចែកចាយ ឬក៏ធ្វើអោយទទួល បានតាមទម្រង់ណាក៏ដោយនូវ៖

ក.១. ឧបករណ៍រួមមានកម្មវិធីកុំព្យូទ័រដែលបង្កើតឡើងឬយកលំនាំតាមសម្រាប់គោល បំណងក្នុងការប្រព្រឹត្តិនូវរាល់បទល្មើសដែលបានចែងក្នុងមាត្រា៥ ដល់មាត្រា១៤ ខាងលើ។

ក.២. អក្ខរក្រមសម្ងាត់កុំព្យូទ័រ កូដភ្ជាប់ ឬក៏ទិន្នន័យប្រហាក់ប្រហែល ដែលផ្នែកទាំង មូលឬផ្នែកណាមួយនោះមានសមត្ថភាពអាចភ្ជាប់ទៅកាន់ប្រព័ន្ធកុំព្យូទ័របាន ក្នុងគោលបំណងប្រព្រឹត្តិនូវរាល់បទល្មើសដែលមានចែកក្នុងមាត្រា៥ ដល់មាត្រា១៤ ខាងលើ ។

ខ. ចំពោះការកាន់កាប់ដោយគ្មានសិទ្ធិនូវរាល់ជាតុផ្សំទាំងឡាយណាដែលមានចែងក្នុងកថា ខណ្ឌ ក.១ ឬ ក.២ ខាងលើ ក្នុងគោលបំណងប្រើប្រាស់ដើម្បីប្រព្រឹត្តនូវរាល់បទល្មើសណាមួយដែល មានចែងក្នុងមាត្រា៥ ដល់មាត្រា១៤ ខាងលើ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំទៅ ៦ (ប្រាំមួយ) ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (មួយលាន) រៀលដល់ ១២ ០០០ ០០០ (ដប់ពីរលាន)រៀល។

២.មិនត្រូវបានរាប់ចូលជាបទល្មើសខាងលើឡើយនៅពេលដែលការ ផលិត ការលក់ ការធ្វើលទ្ធកម្មប្រើ ប្រាស់ ការចែក ចាយ ឬការធ្វើអោយមាន ឬការកាន់កាប់នូវអ្វីដែលមានចែងនៅក្នុង កថាខណ្ឌទី១ ខាងលើមិនមានបំណងក្នុងការប្រព្រឹត្ត បទល្មើសដែលមានចែងក្នុងមាត្រា៥ ដល់មាត្រា១៤ ដូចជាសិទ្ធិអនុញ្ញាតក្នុងការធ្វើកោសល្យវិច័យ ការធ្វើតេស្ត ឬការ ការពារប្រព័ន្ធកុំព្យូទ័រជាដើម។

**មាត្រា ៣៣**.. ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹតបទមជ្ឈឹមដែលមានចែងក្នុងមាត្រា៤២៧ (បទចូលទៅដល់ ឬស្ថិតនៅនឹងប្រព័ន្ធ ប្រព្រឹត្តិ កម្មស្វ័យប្រវត្តិនៃទិន្នន័យ) មាត្រា៤២៨ (បទបង្កើតជាឧបសគ្គដល់ដំណើរការនៃប្រព័ន្ធ ប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ) មាត្រា៤២៩ (បទបញ្ចូល លុបបំបាត់ ឬកែប្រែដោយទុច្ចរិត នូវទិន្នន័យ) មាត្រា៤៣០ (បទចូលរួមក្នុងក្រុមប្រមូលផ្តុំ ឬក្នុងសន្ធិផ្សិកាពដើម្បីរៀបចំប្រព្រឹត្តបទល្មើស) នៃក្រមព្រហ្មទណ្ឌ និងមាត្រា២១(ការភ្ជាប់ដោយខុសច្បាប់) មាត្រា២២ (ចារកម្មទិន្នន័យ) មាត្រា២៣ (ការស្ទាក់ចាប់ដោយខុសច្បាប់) មាត្រា២៤ (ការជ្រៀតជ្រែកទិន្នន័យ) មាត្រា២៥ (ការផ្ទេរទិន្នន័យ ដោយគ្មានការអនុញ្ញាត) មាត្រា២៦ (ការជ្រៀតជ្រែកប្រព័ន្ធ) មាត្រា២៧ (រូបអាសអាភាសកុមារ) មាត្រា២៨ (បទល្មើសទាក់ទងនឹងខ្លឹមសារ) មាត្រា៣០ (ការឆបោកតាមរយៈកុំព្យូទ័រ) មាត្រា៣១ (ការក្លែងបន្លំតាមរយៈកុំព្យូទ័រ) មាត្រា៣២ (ការប្រើឧបករណ៍ក្នុងផ្លូវខុស) នៃច្បាប់នេះ ត្រូវផ្តន្ទាទោស ដូចគ្នានឹងបទមជ្ឈឹមបានសម្រេចដែរ។

**មាត្រា ៣៤**..ទោសបន្ថែមអនុវត្តចំពោះបទល្មើសបច្ចេកវិទ្យា

ចំពោះបទល្មើសបច្ចេកវិទ្យាដូចមានចែងក្នុងច្បាប់នេះ ទោសបន្ថែមមួយឬច្រើនដូចខាង ក្រោមអាចត្រូវបាន ប្រកាស៖

១- ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

២- ហាមឃាត់មិនអោយប្រើប្រាស់កុំព្យូទ័រសម្រាប់រយៈពេលមិនល្មើសពី៥ (ប្រាំ)ឆ្នាំ

៣- ការហាមឃាត់ចំពោះការប្រកបមុខរបរជាស្ថាពរ ឬសម្រាប់រយៈពេលមិនលើសពី៥ (ប្រាំ)ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបមុខរបរ ឬក្នុងឱកាសនៃ ការប្រកបនេះ។

៤- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមាន គោលដៅប្រព្រឹត្តបទល្មើស។

៥- ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។

៦- ការរឹបអូសផលខុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៧- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបាន ប្រព្រឹត្ត។

៨- ការបិទគ្រឹះស្ថានដែលត្រូវបានប្រើប្រាស់សម្រាប់ត្រៀមរៀបចំបល្មើសឬប្រព្រឹត្ត បទល្មើសជាស្ថាពរឬ សម្រាប់រយៈពេលមិនល្មើសពី៥(ប្រាំ)ឆ្នាំ។

៩- ការហាមឃាត់ការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលត្រូវបានប្រើប្រាស់សម្រាប់ត្រៀមរៀបចំបទល្មើសឬប្រព្រឹត្តបទល្មើសជាស្ថាពរឬ សម្រាប់រយៈពេលមិនល្មើសពី៥(ប្រាំ)ឆ្នាំ។

១០- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

១១- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន។

១២- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

១៣- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់ រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន។

**មាត្រា ៣៥**..ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល

នីតិបុគ្គលដែលបានចូលរួមប្រព្រឹត្តបទល្មើសបច្ចេកវិទ្យាដូចដែលមានចែងក្នុងមាត្រា២១ ដល់មាត្រា៣២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ..............រៀលដល់ ......................រៀល និងទទួលទោសបន្ថែមមួយ ឬច្រើនដូចខាងក្រោមនេះ៖

១- ការរំលាយចោល។

២- ការដាក់អោយស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

៥- ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំឬប្រព្រឹត្តបទល្មើស។

៦- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជនឬដែលបានប្រើប្រាស់ដោយសាធារណជន។

៧- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើសឬដែលមានគោលដៅ សម្រាប់ប្រព្រឹត្តបទល្មើស។

៨- ការរឹបអូសនូវវត្ថុឬមូលនិធិដែលជាទីដៅនៃបទល្មើស។

៩- ការរឹបអូសនូវឧបភោគកណ្ឌ សម្ភារៈ និងចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត។

១០- ការបិទផ្សាយនៃសេចក្តីសម្រេចផ្តន្ទាទោស។

១១- ការផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានឬផ្សាយតាមមធ្យោបាយគមនាគមន៍ សោតទស្សន៍។

## ជំពូកទី៥

## ជំនួយផ្នែកច្បាប់ទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងបត្យាប័ន

**មាត្រា ៣៦**..បទប្បញ្ញត្តិដែលត្រូវអនុវត្តក្នុងរឿងបត្យាប័ន

បទប្បញ្ញត្តិនៃជំពូកទី២ មាតិកាទី១ គន្ថីទី៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងរឿងបត្យាប័នទាក់ទងទៅនឹង បទល្មើស ដែលមានចែងក្នុងក្រមនេះ។

**មាត្រា ៣៧**..ជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងករណីបទល្មើសដែលមានចែងក្នុងច្បាប់នេះ

អាជ្ញាធរតុលាការនៃព្រះរាជាណាចក្រកម្ពុជាអាចប្រគល់អំណាចឲ្យទៅអាជ្ញាធរខាងតុលាការមានសមត្ថកិច្ចនៃរដ្ឋបរទេសណាមួយ និងអាចទទួលអំណាចពីអាជ្ញាធរតុលាការនៃរដ្ឋបរទេសណាមួយដែរ ដើម្បី៖

១. ប្រមូលយកសក្ខីកាព ឬយកចម្លើយដែលឆ្លើយតាមផ្លូវតុលាការ។

២. ឱ្យដំណឹងពីលិខិតផ្សេងៗរបស់តុលាការ។

៣. ធ្វើការឆែកឆេរ ឃាត់ទុក និងដកហូត។

៤. ធ្វើការត្រួតពិនិត្យវត្ថុ និងទីកន្លែង។

៥. ផ្តល់ព័ត៌មាន និងវត្ថុតាង។

៦. ផ្តល់ឯកសារកំណត់ហេតុច្បាប់ដើម ឬសេចក្តីចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ តាមច្បាប់ផ្តើមនៃឯកសារ នឹងសំណុំរឿងរាប់ទាំងសេចក្តីស្រង់បញ្ជីប្រាក់ពីធនាគារ ឯកសារគណនេយ្យ សំណុំរឿងរបស់ក្រុមហ៊ុន និងឯកសារពាណិជ្ជ កម្ម ព្រមទាំងលិខិតយថាភូត ឬលិខិតឯកជន។

៧. បង្ហាញ ឬផ្តល់សាក្សីអ្នកជំនាញ ឬជនដទៃទៀត រាប់ទាំងជនឃុំខ្លួនផងដែរដែល យល់ព្រមជួយក្នុងការស៊ើប អង្កេត ឬយល់ព្រមចូលរួមក្នុងនីតិវិធី

៨. កំណត់អត្តសញ្ញាណឬស្រាវជ្រាវរកធនធាន ទ្រព្យសម្បត្តិ បរិក្ខារ និងសម្ភារៈទាំង ឡាយដែលបានមកពីការ ប្រព្រឹត្តបទល្មើសនិងមធ្យោបាយបទល្មើស

៩. ដាក់ក្រោមវិធានការរក្សាទុកជាបណ្តោះអាសន្ននូវផលិតផលនិងទ្រព្យសម្បត្តិ ដែលបានមកពីបទល្មើស បច្ចេកវិទ្យាព្រមទាំងបរិក្ខារសម្ភារៈដែលប្រើប្រាស់ ឬទុកសម្រាប់ប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសបច្ចេកវិទ្យា។

១០. ចាត់ឱ្យអនុវត្តសេចក្តីសម្រេចដែលបញ្ជាឱ្យធ្វើការរឹបអូស ដកហូត ឬយកមកវិញនូវផលិតផល ទ្រព្យសម្បត្តិ បរិក្ខារ សម្ភារៈទាំងឡាយដែលបានមកពីការប្រព្រឹត្ត បទល្មើសបច្ចេកវិទ្យា។

១១. បញ្ជាឱ្យធ្វើការរឹបអូសវត្ថុទាំងឡាយដែលមានចែងក្នុងចំណុចខាងលើ។

១២. ឱ្យដំណឹងអំពីការចោទប្រកាន់តាមនីតិវិធីព្រហ្មទណ្ឌ។

១៣. សួរចម្លើយជនត្រូវចោទតាមនីតិវិធីព្រហ្មទណ្ឌ។

១៤. រកឱ្យឃើញនិងកំណត់អត្តសញ្ញាណសាក្សីនិងជនសង្ស័យ។

**មាត្រា ៣៨**..នីតិវិធីជំនួយផ្នែកច្បាប់ទៅវិញទៅមក

នីតិវិធីនៃការអនុវត្តជំនួយផ្នែកច្បាប់ទៅវិញទៅមក ត្រូវអនុវត្តតាមគោលការណ៍ទាំងឡាយ ដែលបានកំណត់ក្នុងសន្ធិសញ្ញា ឬកិច្ចព្រមព្រៀង ទ្វេភាគី និងពហុភាគី និងច្បាប់ជាតិជាធរមាន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ៣៩**..និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីខ្លឹមសារនៃច្បាប់នេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤០**..ការអនុវត្តច្បាប់នេះ

ច្បាប់នេះត្រូវអនុវត្តក្នុងរយៈពេល ១ (មួយ)ឆ្នាំ ក្រោយការចូលជាធរមាននៃច្បាប់នេះ។